ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី

លេខ៖ ១០៥... "ម"

ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២០

សំណុំរឿងរដ្ឋប្បវេណីលេខ ២២៩៣

ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសាលសវនាការទី "៤" លើសំណុំរឿងរដ្ឋប្បវេណីលេខ ២២៩៣ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រម និងជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ ៖** ឈ្មោះ [redacted] **ស៊ីថា** ភេទស្រី កើតថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន [redacted] ដែលមានតំណាងដោយអាណត្តិលោកមេធាវី [redacted] អត្តលេខ ១៧២១ កញ្ញាមេធាវី [redacted]។

**ចុងចម្លើយ ៖** ឈ្មោះ [redacted] **ប៊ុនធឿន** ភេទប្រុស កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៦២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

## I.អង្គហេតុ និង ចំណុចវិវាទ

**១. ខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ**

១.១ សុំផ្តាច់សមគ្គសង្វាសពីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន តាមការព្រមព្រៀង។

១.២ ទាមទារឱ្យឈ្មោះ [redacted] ប៊ុនធឿន កាត់ឈ្មោះផ្ទេរកម្មសិទ្ធិអចលនវត្ថុឱ្យទៅឈ្មោះ [redacted] ស៊ីថា នូវអចលនវត្ថុតាមការព្រមព្រៀងដូចខាងក្រោម៖

- ដីទំហំ ៤៩៨ម$^2$ មានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ២៨ម$^2$ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។



Scanned with CamScanner

- ដីទំហំ ១៨ម² មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ៤៩ម² មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ផ្ទះលេខ ១បេ មានទីតាំងស្ថិតនៅ ផ្លូវលំ ក្រុម៩ ភូមិឬស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យរាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ។

១.៣ ប្រគល់ទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] ប៊ុនធឿន តាមការព្រមព្រៀង។

## ២. ការពន្យល់គ្រួសៗអំពីអង្គហេតុ

ដើមចោទ និងចុងចម្លើយ បានរៀបការនៅឆ្នាំ១៩៨៧ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ ការរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយមានកូនចំនួន ០៤នាក់ តែកូនៗទាំងនោះមានវ័យនីតិភាពអស់ហើយ។ ក្រោយពេលរៀបការ ដើមចោទ និងចុងចម្លើយរស់នៅមានសុភមង្គលជាធម្មតា លុះមកដល់អំឡុងឆ្នាំ២០១២ ការរស់នៅមិនចុះសម្រុងនឹងគ្នា ទើបដើមចោទបានដាក់ពាក្យបណ្តឹងទាមទារសុំឈប់រស់ជាអនីតិសង្វាស ដោយបង្ហាញមូលហេតុថាការរស់នៅមិនចុះសម្រុង និងអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាបន្តទៀតបាន។ ចំពោះទ្រព្យសម្បត្តិរួមគ្នា រវាងដើមចោទ និងចុងចម្លើយមាន:

- ដីទំហំ ៩៩៨ម² មានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ២៨ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ១៨ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ៤៩ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។



Scanned with CamScanner

- ផ្ទះលេខ ១បេ មានទីតាំងស្ថិតនៅ ផ្លូវលំ ក្រុម៩ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌ មានជ័យ រាជធានីភ្នំពេញ។

## ៣. អង្គហេតុដែលអះអាងដោយដើមចោទ

នាងខ្ញុំ និងចុងចម្លើយបានរៀបការតាមប្រពៃណីនៅឆ្នាំ១៩៨៧ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ នាងខ្ញុំបានដាក់ពាក្យសុំលែងលះពីចុងចម្លើយដោយមូលហេតុការរស់នៅមិនចុះសម្រុងនឹងគ្នា និងអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាបន្តទៀត។ ការរស់នៅជាមួយគ្នារវាងនាងខ្ញុំ និងចុងចម្លើយមានកូនចំនួន ០៤នាក់ តែកូនៗទាំងបួននាក់នោះមានវ័យនីតិភាពអស់ហើយ។ នាងខ្ញុំនិងចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចខាងក្រោម:

- ដីទំហំ ៩៩៨ម² មានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ២៨ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ១៨ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ៥៩ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ផ្ទះលេខ ១បេ មានទីតាំងស្ថិតនៅ ផ្លូវលំ ក្រុម៩ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ចំពោះទ្រព្យសម្បត្តិរួមដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីខាងលើ គឺនាងខ្ញុំស្នើសុំគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ ហើយនាងខ្ញុំសុខចិត្តប្រគល់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកឱ្យទៅចុងចម្លើយ ដូចមាននៅក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលនាងខ្ញុំភ្ជាប់មកជាមួយពាក្យបណ្ដឹងស្រាប់។

## ៤. អង្គហេតុដែលអះអាងដោយចុងចម្លើយ

ចំពោះការអះអាងរបស់ដើមចោទខ្ញុំបាទសុំទទួលស្គាល់ថាពិតជាត្រឹមត្រូវ ខ្ញុំបាទមិនបដិសេធត្រង់ចំណុចណាឡើយ ហើយខ្ញុំបាទសូមបញ្ជាក់ជូនតុលាការថា បើដើមចោទអស់មនោសញ្ចេតនាពីខ្ញុំបាទ និងមិនអាចរស់នៅជាប្ដីប្រពន្ធបានតទៅទៀតបាន ខ្ញុំបាទក៏សុខចិត្តលែងលះជាមួយដើមចោទ និងឯកភាពតាមការទាមទារ របស់ដើមចោទ



Scanned with CamScanner

ខាងលើដោយយល់ព្រមប្រគល់ទ្រព្យសម្បត្តិរួមដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដូចខាងក្រោម៖

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌ មានជ័យ រាជធានីភ្នំពេញ។

ចំណែកខ្ញុំបាទយល់ព្រមទទួលប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ពីដើមចោទដូចមាននៅក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃ ទី២០ ខែធ្នូ ឆ្នាំ២០១៩ ។

## ៥. ចំណុចវិវាទ និងចំណុចគ្មានវិវាទ ៖

៥.១. ចំណុចវិវាទ ៖ គ្មាន។

៥.២. ចំណុចគ្មានវិវាទ ៖

៥.២.១. សុំឈប់រស់នៅជាសង្វាសពីរវាងដើមចោទឈ្មោះ [redacted] ស៊ីថា និងចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន តាមការព្រមព្រៀង។

៥.២.២. ចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន យល់ព្រមប្រគល់ទ្រព្យសម្បត្តិរួមជាអចលនវត្ថុឱ្យទៅដើមចោទឈ្មោះ [redacted] ស៊ីថា ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដូចខាងក្រោម៖

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌ មានជ័យ រាជធានីភ្នំពេញ។

៥.២.៣. ដើមចោទឈ្មោះ [redacted] ស៊ីថា យល់ព្រមប្រគល់ទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន តាមការព្រមព្រៀង។

# II. ការពិនិត្យភស្តុតាង

## ១. ភស្តុតាងជាឯកសាររបស់ដើមចោទ

១.១. កិច្ចព្រមព្រៀងលែងលះ និងបែងចែកទ្រព្យសម្បត្តិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

១.២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១០៣៨៨៥៣ របស់ឈ្មោះ [redacted] ស៊ីថា។



Scanned with CamScanner

១.៣. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៦០៨២៣៧៤៨ របស់ឈ្មោះ [redacted] ប៊ុនធឿន។

១.៤ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

១.៥ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

១.៦ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

១.៧ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

១.៨ លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ។

១.៩ សៀវភៅគ្រួសារ លេខ ០៦០២២២៨៨ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ចេញដោយស្នងការរាជធានីភ្នំពេញ។

២. **ភស្តុតាងជាឯកសាររបស់ចុងចម្លើយ ៖** គ្មាន។

## សំអាងហេតុ

**ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖**

១. យល់ឃើញថា ដើមចោទ និងចុងចម្លើយ បានរៀបការនៅឆ្នាំ១៩៨៧ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ។ ដូច្នេះ ការរស់នៅរបស់ភាគីក្នុងស្ថានភាពជាប្ដីប្រពន្ធ ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ។ ការរស់នៅបែបនេះជាការរស់នៅបែបអនីតិសង្វាស ដោយមិនជាប់ចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ឡើយ។ ការទាមទាររបស់ដើមចោទ ត្រង់ចំណុច សុំឈប់រស់នៅជាអនីតិសង្វាស មិនអាចធ្វើការកែតម្រូវតាមដីកាសម្រេចឱ្យកែតម្រូវដូចមានចែងក្នុងមាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានទេ។ ហេតុដូច្នេះ តុលាការពិចារណាលើកចោលកម្មវត្ថុបណ្ដឹងទាមទារត្រង់ចំណុចទី០១ ដែលមានខ្លឹមសារទាមទារសុំឈប់រស់ជាអនីតិសង្វាសចោល នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២២៩៣ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ដោយតុលាការ មិនលើកយកមកពិចារណា ស្របតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ គូភាគីទាំងពីរមានសិទ្ធិពេញលេញ ក្នុងការយកគូស្រករថ្មីបានរៀងៗខ្លួន ដោយមិនមានការជំទាស់ពីភាគីណាមួយឡើយ។ ក្រៅពីចំណុចទាមទារដូចខាងលើនេះ តុលាការអាចលើកយកចំណុចនៃការប្ដឹងទាមទារផ្សេងៗទៀតរបស់ដើមចោទ នៃសំណុំរឿងរដ្ឋប្បវេណីនេះ មកធ្វើការចាត់ការបានតាមមាត្រា ៣ និងមាត្រា ៥ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. យល់ឃើញថា ចំណុចគ្មានវិវាទមានដូចជា៖

២.១. ដើមចោទឈ្មោះ [redacted] ស៊ីថា សុំឈប់រស់នៅជាអតីតសង្វាសពីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ។

២.២ ចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន យល់ព្រមប្រគល់ទ្រព្យសម្បត្តិរួមឱ្យទៅដើមចោទឈ្មោះ [redacted] ស៊ីថា នូវអចលនវត្ថុដូចដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដូចខាងក្រោម៖

២.២.១ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

២.២.២ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

២.២.៣ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

២.២.៤ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

២.២.៥ លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ។

២.៣ ដើមចោទឈ្មោះ [redacted] ស៊ីថា យល់ព្រមប្រគល់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ។

៣. តុលាការបានពិនិត្យឯកសារភស្តុតាងដែលដើមចោទបានដាក់ជូនតុលាការពិនិត្យរួមមាន ៖

-កិច្ចព្រមព្រៀងលែងលះ និងបែងចែកទ្រព្យសម្បត្តិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១០៣៨៨៥៣ របស់ឈ្មោះ ទេព ស៊ីថា។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៦០៨២៣៧៤៨ របស់ឈ្មោះ ស៊ឹម ប៊ុនធឿន។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦។

- លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាល ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-សៀវភៅគ្រួសារ លេខ ០៦០២២២៨៨ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ចេញដោយស្នងការរាជ ធានីភ្នំពេញ។

៤. ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

សន្និដ្ឋាន៖ ដូចមានបញ្ជាក់ក្នុងសំអាងហេតុខាងលើនេះ គប្បីតុលាការ សម្រេចតាមការទាមទាររបស់ដើមចោទ និងចុងចម្លើយតាមការព្រមព្រៀងរបស់ភាគី ។



Scanned with CamScanner

២. បង្គាប់ឱ្យឈ្មោះ [redacted] ប៊ុនធឿន ផ្ទេរកម្មសិទ្ធិលើអចលនវត្ថុឱ្យទៅឈ្មោះ [redacted] ស៊ីថា ដូចខាងក្រោម៖

- ដីទំហំ ៤៩៨ម² មានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៥០៥១៤-០៤៩០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ២៨ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ១៨ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៥៩៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ដីទំហំ ៤៩ម២ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១២០៦០១០២-០៣៧៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។
- ផ្ទះលេខ ១បេ មានទីតាំងស្ថិតនៅ ផ្លូវលំ ក្រុម៩ ភូមិឬស្សី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បញ្ជាក់ដោយអភិបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ។

៣. ឱ្យដើមចោទឈ្មោះ [redacted] ស៊ីថា ប្រគល់ប្រាក់ ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ទៅចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន តាមការព្រមព្រៀងរបស់ភាគី ។

៤. ឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

**បានឃើញ**

**ចៅក្រម**

[redacted]

**"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

ថ្ងៃសុក្រ ១៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

សាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner